# មនុស្សគ្រប់រូបមានសិទ្ធិទទួលបានជីវិតរស់នៅល្អប្រសើរ ទាំងក្នុងអំឡុង និងក្រោយពេលវិបត្តិកូវីដ-១៩

ទីក្រុងហ្សឺណែវ (១៥ មីនា ២០២២) – រដ្ឋាភិបាលទាំងឡាយ ត្រូវធានាថាមនុស្សគ្រប់រូបទទួលបាននូវបទដ្ឋានរស់នៅសមរម្យ ទោះស្ថិតនៅក្នុងស្ថានភាពនៃវិបត្តិកូវីដ-១៩ ក៏ដោយ។

យោងតាមការលើកឡើងរបស់សេដ្ឋវិទូស្ត្រីនិយម លោកស្រីបណ្ឌិត Savi Bisnath ថា *"រដ្ឋាភិបាលទាំងឡាយមានកាតព្វកិច្ចក្នុងការបំពេញសិទ្ធិទទួលបានសន្តិសុខសង្គម រួមទាំងតាមរយៈការវិភាជន៍ថវិកា ក៏ដូចជាការការពារ និងគោរពសិទ្ធិទាំងនេះតាមរយៈច្បាប់ គោលនយោបាយ និងការរៀបចំផែនការនានា។"*

លោកស្រី Bisnath កំពុងបម្រើការងារនៅការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស នៅទីក្រុងហ្សឺណែវ និងទទួលបន្ទុកនៅតំបន់អាស៊ីប៉ាស៊ីហ្វិកលើការអភិវឌ្ឍផ្នែកដែលឱ្យឈ្មោះថា សេដ្ឋកិច្ចសិទ្ធិមនុស្ស។ លោកស្រីមានប្រសាសន៍ថា រដ្ឋាភិបាលត្រូវតែបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការផ្ដល់ដល់ប្រជាជនរបស់ពួកគេ ដែលនេះជាករណីកិច្ចពាក់ព័ន្ធជាពិសេសមួយក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ ១៩ ពេលបច្ចុប្បន្ន។

បើនិយាយឱ្យជាក់លាក់ ចំណុចនេះសំដៅដល់ការតម្រូវឱ្យមាន "ការសម្រេចចិត្តប្រកបដោយការទទួលខុសត្រូវ" ក្នុងការប្រើប្រាស់ធនធានដែលមានជាអតិបរមា តាមរយៈមធ្យោបាយដូចជា ពន្ធដារ ដើម្បីសម្រេចឱ្យបាននូវសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់មនុស្សគ្រប់គ្នា។

សិទ្ធិទាំងនេះរួមមាន ការទទួលបានការថែទាំសុខភាពប្រកបដោយគុណភាពក្នុងអំឡុងពេលមានវិបត្តិ។ លោកស្រីបណ្ឌិត Bisnath ក៏មានប្រសាសន៍ដែរថា រដ្ឋាភិបាលទាំងឡាយមានកាតព្វកិច្ចធ្វើយ៉ាងណាឱ្យមានតម្លាភាព និងគណនេយ្យភាពចំពោះសកម្មភាពរបស់ពួកគេ ដូច្នេះ ប្រជាជនអាចធ្វើការវាយតម្លៃលើការអនុវត្តរបស់ពួកគេបាន។ វាក៏តម្រូវឱ្យមានការប្រមូលទិន្នន័យផងដែរ ដើម្បីស្វែងយល់កាន់តែច្បាស់ពីតម្រូវការរបស់បុគ្គល ក្រុម និងសហគមន៍ផ្សេងៗគ្នា។

"យើងត្រូវស្វែងយល់អំពីផលប៉ះពាល់នៃជំងឺរាតត្បាតទៅលើថវិកា និងអាយុជីវិតរបស់ប្រជាជន។ យើងត្រូវធ្វើការគណនាថាតើការវិនិយោគលើការចំណាយរបស់សង្គមប៉ុន្មានដែលចាំបាច់ក្នុងគ្រាដែលមានវិបត្តិនេះ ហើយរៀបចំគម្រោងសម្រាប់ពេលដែលជំងឺរាតត្បាតផុតរលត់ទៅ ថាតើនឹងចាំបាច់ត្រូវការការវិនិយោគប៉ុន្មានទៀត។"

## ការផ្តោតសំខាន់ចំពោះស្ត្រី

ការផ្តោតលើស្ត្រីបែបនេះ គឺធ្វើក្នុងន័យដែលធានាថាក្រុមដែលប្រឈមមុខនឹងការរើសអើង គឺត្រូវបានមើលថែជាពិសេស។ យោងតាមរបាយការណ៍របស់ Oxfam ក្នុងឆ្នាំ២០២០ ស្ត្រីបានបាត់បង់ជាង ៦៤ លានការងារ ដោយរងផលប៉ះបាល់ដោយវិបត្តិកូវីដ១៩ ដែលស្មើនឹង ៥ ភាគរយធៀបនឹងការបាត់បង់ចំនួន ៣,៩ ភាគរយសម្រាប់ការងាររបស់បុរស។ ដូចគ្នានេះដែរ នៅក្នុងប្រទេសកម្ពុជា ស្ត្រីក៏ទទួលរងផលប៉ះពាល់អាក្រក់ជាងបុរស។ [របាយការណ៍វិភាគអំពីកូវីដ-១៩ និងយេនឌ័រនៅកម្ពុជា] បានបង្ហាញថាបន្ទុកការងារដែលមិនមានប្រាក់កម្រៃបានកើន

ឡើងសម្រាប់ស្ត្រី និងកុមារី ក្នុងអំឡុងពេលមានវិបត្តិកូវីដ-១៩ ដោយកាន់តែធ្ងន់ធ្ងរហួតទៅ ១០ ដង ចំពោះការងារថែទាំដែលមិនបានទទួលប្រាក់កម្រៃដែលពួកគេបាន និងកំពុងធ្វើរួចហើយ។

លោកស្រីបណ្ឌិត Bisnath លើកឡើងថា "ស្ត្រីរមែងទទួលបានប្រាក់ខែតិចជាងបុរសសម្រាប់ប្រភេទការងារដូចគ្នា។ នៅក្នុងប្រទេសមួយចំនួន ស្ត្រីទទួលបានកម្រៃតិចជាងហួតដល់ ៣០ ភាគរយ ដូច្នេះយើងអាចយល់បានថា ក្នុងករណីមានវិបត្តិ ស្ត្រីនឹងក្លាយជាក្រុមដំបូងគេដែលមិនត្រូវបានគេយកចិត្តទុកដាក់។"

លោកស្រីបណ្ឌិតមានប្រសាសន៍ទៀតថា "ប្រសិនបើយើងមានរដ្ឋាភិបាលដែលគិតគូរពីរឿងនេះ គឺយើងនឹងមានរដ្ឋាភិបាលមួយដែលពិនិត្យមើលថាតើស្ត្រីកំពុងស្ថិតក្នុងស្ថានភាពណាក្នុងសង្គម និងសេដ្ឋកិច្ច និងថាតើពួកគេកំពុងរងផលប៉ះពាល់ដោយវិបត្តិកូវីដយ៉ាងណាខ្លះ ហើយថាតើពួកគេត្រូវការធនធានអ្វីខ្លះទៀតតាមរយៈប្រព័ន្ធសន្តិសុខសង្គម ដើម្បីធានាថាពួកគេមិនជួបស្ថានភាពមិនល្អលើសពីនេះទៅទៀត។"

ចំណុចនេះបានន័យថា រដ្ឋាភិបាលត្រូវតែមានភាពសកម្មត្រៀមជាមុនក្នុងការយកចិត្តទុកដាក់ដល់ក្រុមមនុស្សទាំងនេះ។

"យើងត្រូវការឱ្យមានច្បាប់សម្រាប់ឆ្លើយតបចំពោះបញ្ហាប្រាក់ឈ្នួលស្មើគ្នា ដើម្បីធានាថាស្ត្រីនឹងមានប្រាក់ចំណូលគ្រប់គ្រាន់សម្រាប់សុខភាព ការអប់រំ និងលំនៅឋានសម្រាប់ជីវិតរស់នៅសមរម្យ និងមានបទដ្ឋានគ្រប់គ្រាន់សម្រាប់ការរស់នៅ។"

សិទ្ធិទាំងនេះត្រូវបានដាក់បញ្ចូលក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន និងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដែលជាច្បាប់ស្នូលដ៏សំខាន់ ដែលចែងថា៖ "មនុស្សគ្រប់រូបមានសិទ្ធិទទួលបានបទដ្ឋាននៃការរស់នៅសមរម្យសម្រាប់សុខភាព និងសុខុមាលភាពផ្ទាល់ខ្លួន និងគ្រួសារ រួមទាំងអាហារ សម្លៀកបំពាក់ ផ្ទះសម្បែង និងការថែទាំសុខភាព ព្រមទាំងសេវាសង្គមដែលចាំបាច់នានា។"

លោកស្រីបណ្ឌិត Bisnath មានប្រសាសន៍ទៀតថា គោលនយោបាយសេដ្ឋកិច្ច និងគោលនយោបាយសិទ្ធិមនុស្សមានទំនាក់ទំនងគ្នាទៅវិញទៅមក ហើយ "មិនអាចដំណើរការទៅតែម្ខាងៗបាននោះទេ។"

លោកស្រីបានបន្តថា៖ "នេះជាផ្នែកថ្មីនៃការងារដែលយើងកំពុងប្រឹងប្រែង។ ការងារស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយជាការងាររយៈពេលយូរអង្វែង ... ជាមួយនឹងការងារដែលយើងកំពុងធ្វើលើសិទ្ធិសេដ្ឋកិច្ច និងសង្គម គឺយើងកំពុងកសាងឱ្យមានសង្គមមួយដែលមានទាំងចំណេះដឹង និងការអនុវត្ត។"

**សេដ្ឋកិច្ចសិទ្ធិមនុស្សនៅកម្ពុជា**

អ្នកតំណាងរបស់ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លោក ប្រាឌីប វ៉ាគ្លេ បានមានប្រសាសន៍ថាបទដ្ឋានទាំងនេះគួរតែត្រូវបានដាក់ចេញ និងអនុវត្តនៅបណ្តាប្រទេសផ្សេងៗ ក្រៅពីប្រទេសដែលមានការវិវឌ្ឍ

ខ្លាំងបំផុត រួមទាំងប្រទេសកម្ពុជាផងដែរ ហើយការផ្លាស់ប្តូរបែបនេះនៅក្នុងការគិតគូរ គឺរឹតតែមានសារៈសំខាន់ខ្លាំងនៅពេលនេះ ជាងពេលដែលពិភពលោកមិនទាន់មានជំងឺរាតត្បាត។

លោកលើកឡើងថា "ពិតជាសំខាន់ដែលប្រជាជនដែលរងផលប៉ះពាល់ក្នុងអំឡុងពេលជំងឺរាតត្បាត និងជួបការលំបាកផ្នែកសេដ្ឋកិច្ចសង្គម ត្រូវទទួលបានការថែទាំយ៉ាងត្រឹមត្រូវពីរដ្ឋាភិបាលរបស់ខ្លួន។ ការជួយគាំទ្រគួរតែផ្តល់ឱ្យដល់អ្នកទាំងឡាយណាដែលត្រូវការជាចាំបាច់ ដោយមិនប្រកាន់ពីគោលជំហរនយោបាយ សង្គម និងសេដ្ឋកិច្ចរបស់ពួកគេ។"

លោកបន្តថា អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា កំពុងតែធ្វើដំណើរឆ្ពោះទៅរកការប្រមូលទិន្នន័យដែលអាចជួយកំណត់បង្ហាញ ព្យាករណ៍ និងផ្តោតលើគោលដៅងាយរងគ្រោះផ្នែកសេដ្ឋកិច្ចសង្គម ការរើសអើង និងវិសមភាពផ្នែកទ្រព្យធន និងចំណូល។ ព័ត៌មានអំពីសិទ្ធិមនុស្សទាំងនេះកំពុងតែត្រូវបានប្រើប្រាស់ដើម្បីកំណត់បង្ហាញនូវសហគមន៍ដែលមិនសូវមានការយកចិត្តទុកដាក់ និងដើម្បីជួយជំរុញដល់ការតស៊ូមតិ និងការអនុវត្តកម្មវិធីនានារបស់អង្គការសហប្រជាជាតិនៅកម្ពុជា រួមទាំងការវាយតម្លៃផលប៉ះពាល់ និងហានិភ័យកូវីដ-១៩ របស់អង្គការសហប្រជាជាតិ។

នៅក្នុងប្រទេសផ្សេងទៀត មានឧទាហរណ៍ល្អៗក្នុងការគាំទ្របំលាស់ប្តូរសង្គម និងនយោបាយក្នុងការប្រើប្រាស់វិធាន និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ក្នុងសេចក្តីសម្រេចរបស់តុលាការក្រោមយុត្តាធិការជាតិ ដែលបញ្ហាដូចជាសិទ្ធិទទួលបានលំនៅឋានសមរម្យ សិទ្ធិទទួលបានការថែទាំសុខភាព និងសិទ្ធិទទួលបានស្បៀងអាហារដែលត្រូវបានអត្ថាធិប្បាយថាជា "ជាសិទ្ធិមនុស្សដែលអាចអនុវត្តទៅបាន"។

លោក វ៉ាគ្លេ លើកឡើងថា "យើងត្រូវចាប់ផ្តើមក្រឡេកមើលទៅពិភពលោក តាមរយៈសេដ្ឋកិច្ចដែលមានចរិតលក្ខណៈគាំទ្រដល់អ្នកក្រ និងផ្តោតលើមនុស្ស ជាជាងបន្តអនុវត្តប្រព័ន្ធសង្គមដែលមានម្ចាស់បំណុល និងកូនបំណុល ហើយម្ចាស់ផ្ទះ និងអ្នកបង់ថ្លៃឈ្នួល ដែលមានលក្ខណៈចាស់គំរឹល។"